# ក្រសួងយុត្តិធម៌

មហាវិថីសម្តេចសុធារស ខណ្ឌដូនពេញ រាជធានីភ្នំពេញ

ទូរស័ព្ទ: ០២៣ ២១៦ ៣២២, ០២៣ ២១១ ៦៩៥

# ព្រឹត្តិបត្រថ្កោលទោសលេខ៣

<table>
<tr><td>ឈ្មោះសេវា</td><td>ព្រឹត្តិបត្រថ្កោលទោសលេខ៣</td></tr>
<tr><td>ក្រសួង/ស្ថាប័ន<br>ផ្តល់សេវា</td><td>ក្រសួងយុត្តិធម៌<br>• អគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌ<br>• នាយកដ្ឋានកិច្ចការថ្កោលទោស<br>មហាវិថីសម្តេចសុធារស ខណ្ឌដូនពេញ រាជធានីភ្នំពេញ,<br>ទូរស័ព្ទ: ០២៣ ២១៦ ៣២២, ០២៣ ២១១ ៦៩៥</td></tr>
<tr><td>គោលបំណង<br>នៃការផ្តល់សេវា</td><td>បញ្ជាក់ពីភាពស្អាតស្អំមាន ឬគ្មានទោសរបស់សាមីជនដែលចូលមកសុំព្រឹត្តិបត្រថ្កោលទោសដើម្បីយកទៅប្រើប្រាស់ តាមតម្រូវការ។</td></tr>
<tr><td>មូលដ្ឋានគតិយុត្ត</td><td>• ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌។<br>• ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា មាត្រា១២។<br>• ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៥៤២ ដល់មាត្រា ៥៥២។<br>• អនុក្រឹត្យលេខ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌។<br>• ប្រកាសរួមលេខ១០០១ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ រវាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងក្រសួងយុត្តិធម៌ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងយុត្តិធម៌។</td></tr>
<tr><td>អតិថិជនដែលមាន<br>សិទ្ធទទួលសេវា</td><td>ប្រជាពលរដ្ឋខ្មែរ ឬ ជនបរទេស ដែលចូលមកស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយស្របច្បាប់ និងនីតិបុគ្គលឯកជន។</td></tr>
<tr><td>ស្តង់ដាសេវា</td><td>ការចេញព្រឹត្តិបត្រថ្កោលទោសលេខ៣
<table>
<tr><th>បរិយាយ</th><th>តម្លៃសេវា<br>(រៀល)</th><th>រយៈពេល<br>(ថ្ងៃធ្វើការ)</th><th>សុពលភាព</th></tr>
<tr><td rowspan="2">ព្រឹត្តិបត្រថ្កោលទោស(ជនជាតិខ្មែរក្រៅពីសិស្ស និងនិស្សិត)</td><td>៣០,០០០</td><td>២០ថ្ងៃ</td><td rowspan="2">៣ខែ</td></tr>
<tr><td>៦០,០០០</td><td>១២ថ្ងៃ</td></tr>
<tr><td rowspan="2">ព្រឹត្តិបត្រថ្កោលទោស(ជនជាតិខ្មែរជាសិស្ស ឬនិស្សិត)</td><td>១០,០០០</td><td>២០ថ្ងៃ</td><td rowspan="2">៣ខែ</td></tr>
<tr><td>២០,០០០</td><td>១២ថ្ងៃ</td></tr>
<tr><td rowspan="2">ព្រឹត្តិបត្រថ្កោលទោស(ជនជាតិបរទេស)</td><td>២៥០,០០០</td><td>២០ថ្ងៃ</td><td rowspan="2">៣ខែ</td></tr>
<tr><td>៥០០,០០០</td><td>១២ថ្ងៃ</td></tr>
<tr><td rowspan="2">បកប្រែជាភាសាបរទេស (ព្រឹត្តិបត្រថ្កោលទោស)</td><td>៤០,០០០</td><td>២០ថ្ងៃ</td><td rowspan="2">៣ខែ</td></tr>
<tr><td>៦០,០០០</td><td>១២ថ្ងៃ</td></tr>
</table></td></tr>
<tr><td>តម្រូវការឯកសារ<br>ដើម្បីទទួលបានសេវា</td><td><u>សម្រាប់ជនជាតិខ្មែរៈ</u><br>• ពាក្យសុំព្រឹត្តិបត្រថ្កោលទោស ០១ច្បាប់ មានបិទរូបថត ៤X៦ = ១ សន្លឹក<br>• ប្រវត្តិរូបសង្ខេប ០១ ច្បាប់<br>• សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ច្បាប់ដើម ០១ ច្បាប់ និងថតចម្លង ស-ខ្មៅ ០១ច្បាប់<br>• សៀវភៅស្នាក់នៅថតចម្លង ស-ខ្មៅ ០១ច្បាប់។<br>• ប័ណ្ណសំគាល់ខ្លួន ជាសិស្ស-និស្សិត (បើនៅរៀន) ដែលមានសុពលភាពភ្ជាប់មកជាមួយ។</td></tr>
</table>

| | |
|---|---|
| | <u>**សម្រាប់ជនជាតិបរទេស:**</u><br>• ពាក្យសុំព្រឹត្តិបត្រថ្កោលទោស ០១ច្បាប់ មានបិទរូបថត ៤X៦ = ១ សន្លឹក<br>• ប្រវត្តិរូបសង្ខេប ០១ ច្បាប់<br>• លិខិតបញ្ជាក់ទីលំនៅ ដែលធ្លាប់បានស្នាក់នៅក្នុងប្រទេសកម្ពុជា ចេញដោយអាជ្ញាធរមានសមត្ថកិច្ច (មេឃុំ,ចៅសង្កាត់) របស់កម្ពុជា ០១ច្បាប់។<br>• សេចក្តីថតចម្លងលិខិតឆ្លងដែន និងទិដ្ឋាការ (Visa) នៅមានសុពលភាព ០១ច្បាប់។<br><u>**បញ្ជាក់:**</u> សម្រាប់ជនជាតិខ្មែររស់នៅក្រៅប្រទេស ឬជនជាតិបរទេសដែលធ្លាប់ស្នាក់នៅកម្ពុជា ហើយត្រឡប់ទៅបរទេសវិញ ការផ្តល់ប្រវត្តិរូបសង្ខេប ត្រូវធ្វើតាមទូតសារដោយបញ្ជាក់ពីអាស័យដ្ឋានបច្ចុប្បន្ននៅបរទេស និងរយៈពេលស្នាក់នៅកម្ពុជា ពីថ្ងៃខែឆ្នាំ ដែលបានចេញ-ចូល ប្រទេសកម្ពុជា ដោយមានផ្តិតស្នាមមេដៃសាមីខ្លួន ចំនួន០១ច្បាប់។ |
| **យោបល់** | **សាមីជន** ដែលមកសុំព្រឹត្តិបត្រថ្កោលទោសលេខ៣ ដើម្បីយកទៅប្រើប្រាស់ សូមគិតអំពីរយៈពេល ដែលក្រសួងយុត្តិធម៌អាចចេញជូនបាន គឺរយៈពេល១២ថ្ងៃ និងរយៈពេល២០ថ្ងៃ **នៃថ្ងៃធ្វើការ** ព្រមទាំងឯកសារពាក់ព័ន្ធ ដែលតម្រូវដោយក្រសួងយុត្តិធម៌ ដូចមានរៀបរាប់ខាងលើ។ |